# អូរស្ការច **A1 & A4i**



| | | |
|---|---|---|
| **ខេត្ត** | : | ព្រះវិហារ |
| **ស្រុក** | : | ឆែប ជាំក្សាន្ត និង ត្បែងមានជ័យ |
| **ផ្ទៃដី ( ហិកតា)** | : | ៨០.៤២៦ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៤៦ ដល់ ១៥៤ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១៣° ៥៨′ ជ ១០៥° ០៨′ ក |

**ការពិពណ៌នាទីកន្លែង**

តំបន់ IBA នេះ ស្ថិតនៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងផ្នែកខាងលើដងស្ទឹងសែន គ្របដណ្ដប់លើសលប់ដោយប្រភេទព្រៃរបោះ នៅតាមកន្លែងខ្លះគ្របដណ្ដប់ដោយព្រៃស្រោង និង ព្រៃពាក់កណ្ដាលស្រោង ។ តំបន់នេះមានដង់ស៊ីតេខ្ពស់នៃតំបន់ដីសើម រួមមានទន្លេ ស្ទឹង ព្រែក បឹង បួរ ជាច្រើន និង ស្ថិតនៅក្នុងតំបន់ព្រៃសម្បទានរបស់ក្រុមហ៊ុន Chendar Plywood ហើយជាប់ទៅនឹងតំបន់ព្រៃអភិរក្សធនធានសេនេទិច និង សត្វព្រៃ "ព្រះវិហារ" ដែលទើបត្រូវបានបង្កើតឡើង និង ជាប់នឹងស្រុកជាំក្សាន្ត ។ តំបន់ IBA នេះមានសារៈសំខាន់សម្រាប់ការអភិរក្សប្រភេទសត្វស្លាបព្រៃមួយចំនួន រួមមាន ក្ងោក ស្ដេចកូលីត និង កេងកងធំ ។ ជាការកត់សំគាល់បំផុតនោះគឺ តំបន់នេះបានទ្រទ្រង់តំបន់ពងកូនរបស់ប្រភេទទាព្រៃស្លាបសនៅក្នុងប្រទេសកម្ពុជា ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 | |
| ក្ងោក | Green Peafowl | *Pavo muticus* | A1 | |
| ទាព្រៃស្លាប ស | White-winged Duck | *Cairina scutulata* | A1 | A4i |
| ស្ដេចកូលីត | Siamese Fireback | *Lophura diardi* | A1 | |

**ប្រភេទសត្វប្រមូលផ្ដុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបបីប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ បួនប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង មួយប្រភេទរស់នៅក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ្ជិប្រផេះ ស្វាត្រោស ស្វាព្រាម និង ទោចម្កុដ ។

**ដំរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

ដំរី ខ្ទីង និង ទន្សោង ។

**ប្រភេទអណ្ដើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

កន្ធាយអាស៊ី ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការគំរាមកំហែងមួយនៃការគំរាមកំហែងចំបងជាច្រើននៅក្នុងតំបន់ IBA នេះ គឺការបាត់បង់ទីជំរកដោយសារការកាប់ព្រៃឈើទាំងស្របច្បាប់ និង ខុសច្បាប់ ជាពិសេសសកម្មភាពនេះធ្វើឱ្យមានការថយចុះដើមឈើធំៗមួយចំនួនដែលមានសារៈសំខាន់សម្រាប់រាល់ប្រភេទសត្វស្លាបដែលធ្វើសំបុកនៅក្នុងរូងឈើ ដូចជាទាព្រៃស្លាបសជាដើម ។ ជាងនេះទៀត ការប្រមាញ់កើតមានជាច្រើននៅក្នុងតំបន់នេះ ជាពិសេសការប្រមាញ់ដោយឆ្កែដែលជាការគំរាមកំហែងយ៉ាងខ្លាំងទៅលើប្រភេទកូនទាព្រៃស្លាបសដែលមិនទាន់ចេះហើរ ឬ ក៏កំពុងចម្រុសរោមនៅក្នុងអំឡុងរដូវវស្សា ។ ក្រៅពីនោះ ការរំខានបង្កដោយអ្នករុករកជ័រដែលធ្វើដំណើរ និង បោះជំរុំស្នាក់នៅបណ្តោះអាសន្នតាមបណ្តោយដងស្ទឹងក៏ជាការគំរាមកំហែងមួយផងដែរ ។

**អនុសាសន៍**

កំណត់តំបន់ដីសើមតាមដងទន្លេសំខាន់ៗសម្រាប់ប្រភេទទាព្រៃស្លាបស ជាតំបន់ការពារពិសេសសម្រាប់ការអភិរក្សជីវៈចំរុះនៅក្នុងផែនការគ្រប់គ្រងព្រៃសម្បទាន ហើយវាគួរតែធានាបានថា តំបន់ទាំងនោះមិនត្រូវបានធ្វើការកាប់ឈើតទៅទៀត ឬ មិនត្រូវឱ្យមានការរំខានដល់សត្វព្រៃឡើយ ។

បង្កើតឡើងនូវកិច្ចព្រមព្រៀងនៃការប្រមាញ់តាមសហគមន៍ក្នុងការកំណត់នៃការប្រើប្រាស់ឆ្កែ និង បង្កើនចំណេះដឹងតាមបណ្តាភូមិនានាទាក់ទងទៅនឹងប្រភេទទាព្រៃស្លាបស ។

ត្រូវធ្វើយ៉ាងណាដើម្បីធានាឱ្យបានថា សកម្មភាពកាប់ឈើទាំងអស់កើតឡើងដោយតម្រូវការស្របច្បាប់ ជាការអនុវត្តន៍មួយយ៉ាងល្អ ។

ប្រធានក្រុមហ៊ុន និង បុគ្គលិកទាំងអស់គួរតែជម្រុញការអនុវត្តន៍ច្បាប់ និង គោលការណ៍ទាំងឡាយ ដើម្បីកុំឱ្យមានការបរបាញ់សត្វព្រៃកើតមាននៅក្នុងដែនព្រៃសម្បទានរបស់ខ្លួន ។

**ឯកសារយោង**

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Tan Setha and Song Chansocheat (2002) *White-winged Duck survey in Chendar Plywood Forest Concession.* Unpublished report to the Wildlife Conservation Society Cambodia Program.